ប្រការ ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តសេចក្ដីសំរេច នេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## III- ការងារបណ្ដាក្រសួង

### ១-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០១

**សេចក្ដីប្រកាស លេខ ១៨០ សប្រក.កសក**

**ស្ដីពី**

**ការហាមឃាត់ការធ្វើអាជីវកម្ម ការប្រមូលទិញ**

**ការកែច្នៃម្សៅខ្លឹមម្រៀត និង ខ្លឹមម្រៀត**

៚

រាជរដ្ឋាភិបាល បាននិងកំពុងបន្តពង្រឹងលុបបំបាត់សកម្មភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ ដោយបានដាក់ចេញលិខិតបទដ្ឋាន និងបទបញ្ជាជាច្រើន ដូចជា : បទបញ្ជាលេខ ០២ បជ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៩ សេចក្ដីប្រកាសលេខ ០១ ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៩ និងចាត់វិធានការអនុវត្តបទបញ្ជាយ៉ាងម៉ឺងម៉ាត់បំផុត ដោយមានការចូលរួម និងគាំទ្រពីគ្រប់ជាន់ថ្នាក់នៃកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិអាជ្ញាធរមូលដ្ឋាន គ្រប់ស្ថាប័នពាក់ព័ន្ធ និងសហគមន៍អន្តរជាតិទទួលបានលទ្ធផលជាទីមោទនៈ ក្នុងការលុបបំបាត់នូវសកម្មភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើដែលមានទ្រង់ទ្រាយធំៗ ។ ប៉ុន្តែបច្ចុប្បន្ននេះ បានកើតឡើងនូវបាតុភាពធ្វើអាជីវកម្មខ្លឹមម្រៀត និងរោងសិប្បកម្ម កែច្នៃខ្លឹមម្រៀតនៅតាមបណ្ដាខេត្ត-ក្រុង មួយចំនួន ដែលជាករណីមួយបង្កឱ្យមានភាពអនាធិបតេយ្យ លើវិស័យព្រៃឈើ ដោយការធ្វើ

អាជីវកម្មវល្លិ៍រមៀត ត្រូវកាប់រំលំដើមឈើធំៗ ដើម្បីយកវល្លិ៍រមៀត ។ ពិសេសការបង្កើតរោងសិប្បកម្មកែច្នៃវល្លិ៍រមៀតបានធ្វើឱ្យបំពុលបរិស្ថាន និងធ្វើឱ្យប៉ះពាល់ដល់សុខភាពប្រជាជន ដែលរស់នៅជុំវិញរោងសិប្បកម្មផង ។

ដើម្បីជាវិធានការទប់ស្កាត់បាតុភាពអនាធិបតេយ្យខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សំរេចដាក់ចេញនូវវិធានការដូចខាងក្រោម :

១-ហាមដាច់ខាតការធ្វើអាជីវកម្ម ការប្រមូលទិញ ការកែច្នៃវល្លិ៍រមៀត និងដឹកជញ្ជូនម្សៅវល្លិ៍រមៀត ។

២-រាល់គោលការណ៍អនុញ្ញាតឱ្យធ្វើអាជីវកម្មវល្លិ៍រមៀត ត្រូវទុកជាមោឃៈ ។

៣-នាយកដ្ឋានរុក្ខាប្រមាញ់ មានភារកិច្ចទទួលខុសត្រូវលើការងារត្រួតពិនិត្យ និងទប់ស្កាត់រាល់សកម្មភាពធ្វើអាជីវកម្ម ការប្រមូលទិញ និងការកែច្នៃវល្លិ៍រមៀត នៅគ្រប់ខេត្ត-ក្រុង ទូទាំងប្រទេស ។

ទទួលបានសេចក្តីប្រកាសនេះ អគ្គនាយកក្រសួង អគ្គាធិការ ប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

រដ្ឋមន្ត្រីស្តីទី

ហត្ថលេខា និងត្រា

**ចំនួ គុងអ៊ីច**

***

## ២~ ទីស្តីការរដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា

## សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០១

**សេចក្តីសំរេច លេខ ១២៣ កធស.សរ**

~~~

**រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា**

៚

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
~~~